**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ខេត្តកំពង់ស្ពឺ**

លេខ: ៣១៨៧ កសរន.កស្ព ថ្ងៃសៅរ៍ ៣កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

ខេត្តកំពង់ស្ពឺ,ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៩

**<u>សូមគោរពជូន</u>**

**លោកអគ្គលេខាធិការរង និងជាប្រធានគ្រប់គ្រងគម្រោង CoWES**

**កម្មវត្ថុ ៖** សំណើសុំធ្វើវិសោធនៈកម្មលើអនុស្សរណៈកិច្ចព្រមព្រៀងចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨។

**យោង ៖** អនុស្សរណៈនៃកិច្ចព្រមព្រៀងរវាងគម្រោង (CoWES) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨។

- របកគំហើញ និងអនុសាសន៍របស់របស់ទីប្រឹក្សាវាយតម្លៃពាក់កណ្តាលអាណត្តិគម្រោង។
- ស្មារតីកិច្ចប្រជុំគណៈកម្មាការដឹកនាំ និងតម្រង់ទិសគម្រោង នាថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ស្តីពីការអនុវត្តសកម្មភាពការងារ និងថវិកា សម្រាប់អនុវត្តគម្រោងឆ្នាំ២០១៩-២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា៖ ដើម្បីអនុវត្តគម្រោងទទួលបានលទ្ធផលឲ្យកាន់ប្រសើរឡើងថែមទៀត ស្របតាមសេចក្តីសម្រេច របស់គណៈកម្មាការដឹកនាំ និងតម្រង់ទិសគម្រោង ក្របខ័ណ្ឌពេលវេលាបទពិសោធន៍ក្នុងការអនុវត្តសកម្មភាពមួយរយៈពេលកន្លងមក និងអនុលោមតាមអនុសាសន៍របស់ទីប្រឹក្សាវាយតម្លៃពាក់កណ្តាលអាណត្តិគម្រោង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមស្នើធ្វើវិសោធនកម្មលើអនុស្សរណៈដូចយោងខាងលើ ដោយសុំរក្សាទុកនូវផ្នែកខ្លះដែលបាននឹងកំពុងអនុវត្តបន្ត និងស្នើសុំបន្ថែមសកម្មភាពមួយចំនួនទៀតដូចខាងក្រោម៖

+**លទ្ធផលផ្ទាល់ទី១.៣៖** ការប្រើប្រាស់ដីដ៏ត្រឹមត្រូវបានអនុវត្តបង្ហាញជូនក្រុមហ៊ុនមានទំហំដីមធ្យមទៅធំ

-សកម្មភាពទី១.៣.១៖ រៀបចំកិច្ចប្រជុំជាមួយម្ចាស់កម្មសិទ្ធិដី(ទំហំធំ) និង ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច (ដំណាំកសិ ឧស្សាហកម្ម) ដើម្បីកំណត់ពីបញ្ហា និងឱកាស។

-សកម្មភាពទី១.៣.២៖ អនុវត្តបង្ហាញពីរបៀបដាំដុះ និងការគ្រប់គ្រងដីដោយចីរភាព ដោយសហការជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច (ដំណាំកសិ ឧស្សាហកម្ម) និងម្ចាស់កម្មសិទ្ធិដីធំៗ។

+**លទ្ធផលផ្ទាល់ទី២.១៖** សកម្មភាពជាអាទិភាព ដើម្បីពន្លឿនការអនុវត្តសកម្មភាពរបស់ព្រៃឈើ ត្រូវបានរំលេចក្នុងកម្មវិធីសកម្មភាព របស់អាជ្ញាធរមូលដ្ឋាន និងក្រសួងកសិកម្ម

-សកម្មភាពទី ២.១.១៖ ចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់សហគមន៍ ព្រមទាំងអាជ្ញាធរមូលដ្ឋាន នៅឃុំស្រុកគោលដៅរបស់គម្រោង។

+**លទ្ធផលផ្ទាល់ទី២.២៖** យុទ្ធសាស្រ្តស្តារព្រៃឈើសមស្រប និងសហគ្រាស សម្រាប់បង្កើតមុខរបរចិញ្ចឹមជីវិតត្រូវបានអនុវត្តបង្ហាញជូនសមាជិកសហគមន៍។

អាសយដ្ឋានៈភូមិចំការដូង សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
Chamkadong Village, Chbamorn Commune, Chbamorn District, Kg.Speu Province.
ទូរស័ព្ទលេខ: (០២៥) ៩៨៧ ២៤៤ / ៩៨៧ ៣២៦ ទូរសារលេខ:០២៥ ៩៨៧ ៣២៦
Phone. (025) 987 244 / 987 326, Fax. (855) 25-987 326

-សកម្មភាពទី ២.២.១៖ ជ្រើសរើសទីប្រឹក្សាបច្ចេកទេសវាយតម្លៃ និងស្តារធនធានព្រៃឈើ (មានលំអិតក្នុងល័ក្ខខ័ណ្ឌការងារជាកិច្ចព្រមព្រៀង)។

-សកម្មភាពទី ២.២.២៖ រៀបចំឯកសារបច្ចេកទេសសម្រាប់បណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រដាំ និងស្តារព្រៃឈើឡើងវិញ។

-សកម្មភាពទី២.២.៣៖ ដំណើរការបណ្តុះបណ្តាលដល់សហគមន៍ និងរដ្ឋបាល មូលដ្ឋានស្តីពីវិធីសាស្ត្រដាំ និងស្តារព្រៃឈើឡើងវិញ និងការផ្គត់ផ្គង់កូនឈើ។

-សកម្មភាពទី២.២.៤៖ រៀបចំ និងដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសជាមួយភា គីពាក់ព័ន្ធដើម្បីត្រួតពិនិត្យលើវឌ្ឍភាព និងផ្តល់អនុសាសន៍បច្ចេកទេសក្នុងសមាភាគទី១ និង ទី២។

ចំពោះខ្លឹមសារសកម្មភាពការងារលំអិត និងទំហំថវិកា (មានឯកសារឧបសម្ព័ន្ធជូនភ្ជាប់) ដែលបានអនុវត្តកន្លងមក និងត្រូវអនុវត្តបន្ត ចាប់ពីពេលនេះតទៅរហូតដល់ពេលបញ្ចប់កិច្ចព្រមព្រៀង។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូមលោកប្រធានគ្រប់គ្រងគម្រោងមេត្តាពិនិត្យជូនជ្រាប និងស្នើសុំការសម្រេចតាមការគួរដោយក្តីអនុគ្រោះ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្មគ្រ័អំពីខ្ញុំ។

**អនុប្រធានមន្ទីរ**

**ប្រធានគ្រប់គ្រងគម្រោង(CoWES)ថ្នាក់ខេត្ត**

**យឹម_ណាន**

**<u>ចម្លងជូន</u>**

-លេខាធិការដ្ឋានគម្រោងCoWES

-ទីប្រឹក្សាគម្រោងCoWES

"ដើម្បីគោរពជូនជ្រាប"

-គ្រប់មន្ត្រីអនុវត្តគម្រោង CoWES ខេត្ត

"ដើម្បីជ្រាប និងអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

27.5.19

ឧបសម្ព័ន្ធ ភ្ជាប់សំណើសុំធ្វើវិសោធនៈកម្មលើអនុស្សរណៈកិច្ចព្រមព្រៀងចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

**ដៃគូអនុវត្ត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

Award ID: 00090509

Porject ID: 00096237

**ដៃគូបន្ទាប់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ**

ឈ្មោះគម្រោង ស្ដីពីការគ្រប់គ្រងរួមគ្នា ដើម្បីការពារ និងស្ដារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាន នៅតំបន់ជួរភ្នំក្រវ៉ាញ់ ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត(CoWES)។

រយៈពេល ខែកញ្ញា ២០១៨ ដល់ ខែឧសភា ២០២០

| ល.រ | សកម្មភាពសំខាន់ៗ | ឯកត្តា | មនុស្ស | ថ្ងៃ | បរិមាណ | ថ្ងៃ/ឯកត្តា | សរុប($) |
|---|---|---|---|---|---|---|---|
| **លទ្ធផលផ្ទាល់ទី១.៣៖ ការប្រើប្រាស់ដីដ៏ត្រឹមត្រូវបានអនុវត្តបង្ហាញជូនក្រុមហ៊ុនមានទំហំដីមធ្យមទៅធំ** | | | | | | | |
| ១.៣.១ | រៀបចំកិច្ចប្រជុំជាមួយម្ចាស់កម្មសិទ្ធិដី (ទំហំធំ) និង ក្រុមហ៊ុនកសិ ឧស្សាហកម្មដើម្បីកំណត់ពីបញ្ហា និងឱកាស។ | សរុប | | | | | ៣.០០០ |
| ១.៣.២ | អនុវត្តបង្ហាញពីរបៀបដាំដុះ និងការគ្រប់គ្រងដីដោយចីរភាពដោយសហការជាមួយក្រុមហ៊ុនកសិឧស្សា ហកម្ម និងម្ចាស់កម្មសិទ្ធិដីធំៗ។ | សរុប | | | | | ១០.០០០ |
| **លទ្ធផលផ្ទាល់ទី២.១៖សកម្មភាពជាអាទិភាព ដើម្បីពន្លឿនការអនុវត្តសកម្មភាពរបស់ព្រៃឈើ ត្រូវបានរំលេចក្នុងកម្មវិធីសកម្មភាព របស់អាជ្ញាធរមូលដ្ឋាន និងក្រសួងកសិកម្ម** | | | | | | | |
| ២.១.១ | ចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន នៅឃុំ ស្រុកគោលដៅរបស់គម្រោង | សរុប | | | | | ១.៥០០ |
| **លទ្ធផលផ្ទាល់ទី២.២ ៖ យុទ្ធសាស្ត្រស្ដារព្រៃឈើសមស្រប និងសហគ្រាសបង្កើតមុខរបរចិញ្ចឹមជីវិតត្រូវបានអនុវត្តបង្ហាញ** | | | | | | | |
| ២.២.១ | ទីប្រឹក្សាបច្ចេកទេសវាយតម្លៃ និងស្ដារធនធានព្រៃ ឈើ (មានលំអិតក្នុងល័ក្ខខ័ណ្ឌការងារ) | សរុប | | | | | ៥.០០០ |
| ២.២.២ | រៀបចំឯកសារបណ្ដុះបណ្ដាល ស្ដីពីវិធីសាស្ត្រដាំ និងស្ដារព្រៃឈើឡើងវិញ | សរុប | | | | | ១៥០ |
| ២.២.៣ | បណ្ដុះបណ្ដាលដល់សហគមន៍ និងរដ្ឋបាលមូលដ្ឋានពីវិធីសាស្ត្រដាំ និងស្ដារព្រៃឈើឡើងវិញ និងការផ្គត់ផ្គង់កូនឈើ | សរុប | | | | | ២.០០០ |
| ២.២.៤ | រៀបចំ និងដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសជា មួយភាគីពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើវឌ្ឍភាព និងផ្ដល់អនុសាសន៍បច្ចេកទេសក្នុងសមាភាគទី១ និង ទី២ | សរុប | | | | | ២.០០០ |
| **សរុបចំណាយរួម (ទាំងអស់)** | | | | | | | ២៣.៦៥០ |